## ខ្លឹមសារសង្ខេបនៃកម្រងឯកសារ ស្តីពីការគ្រប់គ្រងហានិភ័យទាក់ទងបរិស្ថាន និងសង្គម

គម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជំហានទី៣ (LASED-III) នឹងបន្តការគាំទ្រសម្បទានដីសង្គមកិច្ច នៅថ្នាក់ឃុំ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលគម្រោងជំហានដំបូង និងជំហាន២ បាន និងកំពុងផ្តល់ជូនគ្រួសារក្រីក្រដែលគ្មានដីសង់លំនៅដ្ឋាន។ គម្រោងជំហាន៣ ក៏នឹងជួយគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ដែលជាកម្មវិធីរបស់រាជរដ្ឋាភិបាលផងដែរ តាមរយៈការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLT) និងការផ្តល់សម្បទានដីសង្គមកិច្ច (SLC) ជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងពង្រីកមុខរបរចិញ្ចឹមជីវិត។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) គឺជាស្ថាប័នដឹកនាំការអនុវត្តគម្រោងមួយនេះ ឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នថ្នាក់ក្រោមជាតិក្នុងខេត្តគោលដៅ ជាភាគីអនុវត្ត។

ក្របខណ្ឌការងារដើម្បីគ្រប់គ្រងបរិស្ថាននិងសង្គម ត្រូវបានតាក់តែងឡើងដោយពណ៌នាយ៉ាងល្អិតល្អន់ អំពីនីតិវិធី និងតម្រូវការរបស់ស្ថាប័ននីមួយៗ ជួយតម្រង់ទិសក្នុងការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន៣ និងដើម្បីធានាឱ្យបាននូវភាពស្របគ្នា ជាមួយនឹងស្តង់ដារ បរិស្ថាននិងសង្គមរបស់ធនាគារពិភពលោក ក៏ដូចជាច្បាប់នានារបស់កម្ពុជាផងដែរ។ តម្រូវការក្នុងការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម រួមទាំងច្បាប់ភូមិបាល (ឆ្នាំ២០០១) និងអនុនីតិកម្មនានា រាប់បញ្ចូលទាំង ក្របខណ្ឌការងារសម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLT) និងការផ្តល់សម្បទានដីសង្គមកិច្ច (SLC) និងច្បាប់ការងារ (ឆ្នាំ១៩៩៧) ច្បាប់ការពារបរិស្ថាន និងច្បាប់ធនធានធម្មជាតិ (ឆ្នាំ១៩៩៦) ច្បាប់ព្រៃឈើ (ឆ្នាំ២០០២) និងច្បាប់ស្តីពីការការពារបេតិកភណ្ឌវប្បធម៌ជាតិ (ឆ្នាំ១៩៩៦)។ គេបានកំណត់នៅក្នុងឯកសាររបស់ធនាគារពិភពលោក ស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម ភាគទី១ ដល់ទី១០ (ESS1-ESS10) លើកលែងតែភាគទី៩ ដែលមិនត្រូវបានយកមកអនុវត្តនៅក្នុងគម្រោងនេះ (អន្តរការីហិរញ្ញវត្ថុ)។ ការវិភាគគម្លាតនៃនិតិកម្មនៅកម្ពុជា ឆ្លើយតបសុវត្ថិភាពបរិស្ថាន និងសង្គម នឹងមានអធិប្បាយនៅក្នុងឯកសារ ស្តីពីក្របខណ្ឌការងារគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ជាមួយនឹងវិធានការណ៍បំពេញចន្លោះប្រហោងក្នុងអំឡុងពេលអនុវត្តគម្រោង។

ស្ថាប័ន ឬភាគីអនុវត្ត មានបទពិសោធន៍ប្រើប្រាស់ក្របខណ្ឌការងារស្តីពីការការពារបរិស្ថាននិងសង្គម (របស់ធនាគារពិភពលោក) ក្នុងពេលអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានដំបូង និងជំហាន២ ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលិកនិងមន្ត្រីអនុវត្តគម្រោង នៅមិនទាន់យល់ដឹងច្បាស់ អំពីវិសាលភាពដែលគេបានកំណត់បន្ថែមទៀតនៅក្នុងបទដ្ឋានបរិស្ថាននិងសង្គម ព្រមទាំងនីតិវិធីគ្រប់គ្រងហានិភ័យចំពោះបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោកនោះទេ។ ជាមួយគ្នានេះដែរ គេក៏សង្កេតឃើញមានការផ្លាស់ប្តូរក្របខ័ណ្ឌច្បាប់នៅក្នុងប្រទេសកម្ពុជាផងដែរ ជាពិសេសសិទ្ធិកាន់កាប់ដីធ្លី និងការតាំងទីលំនៅថ្មី។ ម្យ៉ាងវិញទៀតបុគ្គលិក និងមន្ត្រីអនុវត្តគម្រោង ក៏មិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ ក្នុងការគ្រប់គ្រងហានិភ័យដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិចនៅឡើយទេ។ អនុលោមតាមឯកសាររបស់ធនាគារពិភពលោក ស្តីពីបទដ្ឋានទី១ នៃបរិស្ថាន និងសង្គម (ESS2) ផ្តោតលើលក្ខខណ្ឌ

ការងារ និងពលកម្ម គឺមានភាពស្របគ្នាទៅនឹងច្បាប់ការងាររបស់កម្ពុជា ដែលមានការអនុវត្ត ជាពិសេសតែក្នុងវិស័យឧស្សាហកម្មសំណង់ តែបទដ្ឋានទី១ តម្រូវឱ្យមានការអនុវត្តលើសពីនេះ ហេតុនេះទើបទាមទារឱ្យមានការពង្រឹងសមត្ថភាពដើម្បីធានាថា គម្រោងត្រូវបានអនុវត្តគ្រប់ជ្រុងជ្រោយ។

ក្របខណ្ឌការងារស្តីពីការគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) ត្រូវបានតាក់តែងឡើង ដោយផ្អែកលើមេរៀនបទពិសោធន៍ដែលទទួលបានពីការអនុវត្តគម្រោងមុនៗ (LASED និង LASED-II)។ គួរកត់សម្គាល់ផងដែរថា ដំណើរការកំណត់អត្តសញ្ញាណដីសម្រាប់រៀបចំផែនទី ការផ្តល់សិទ្ធិកាន់កាន់ដីធ្លី និងការបែងចែកដីធ្លីរបស់គម្រោង ទទួលបានជោគជ័យគួរកត់សម្គាល់ក្នុងការជៀសផុតពីផលប៉ះពាល់ជាអវិជ្ជមានដល់សប្បទានិក (អ្នកប្រើប្រាស់ដី) ទោះជាយ៉ាងណាក៏ដោយ ការទាមទារ តវ៉ា ក៏អាចនឹងកើតមានឡើងមិនអាចជៀសផុតនៅគម្រោងខាងមុខ ហេតុនេះហើយត្រូវការការគ្រប់គ្រងបញ្ហាទាំងអស់នេះ ប្រកបដោយតម្លាភាពជាទីបំផុត។ យន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោងជំហាន២ (LASED-II) ត្រូវបានកត់សម្គាល់ឃើញថា មិនមានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ។ ទោះបីការអនុគម្រោងហេដ្ឋា-រចនាសម្ព័ន្ធ បានជៀសផុតពីផលប៉ះពាល់ដីកម្មសិទ្ធិដែលអាចត្រូវគេទាមទារសំណង ប៉ុន្តែក៏ត្រូវត្រៀមលក្ខណៈ សម្រាប់កន្លែងផ្សេងទៀត បើមានការប៉ះពាល់។ ការចេញបណ្ណកម្មសិទ្ធិដីធ្លី ក្នុងទីតាំងគម្រោងសម្បទានដីសង្គមកិច្ច និងការកំណត់ព្រំប្រទល់នៃតំបន់ទាំងនោះ ក៏ត្រូវបានកត់សម្គាល់ថា មិនទាន់ទទួលបានជោគជ័យពេញលេញនៅឡើយដែរ ក្នុងន័យធានាសុវត្ថិភាពទទួលសិទ្ធិកាន់កាប់ដីធ្លីរបស់សម្បទានិក។ ការអនុវត្តអនាម័យ និងការគ្រប់គ្រងសំណល់រឹង នៅតាមទីតាំងគម្រោងសម្បទានដីសង្គមកិច្ចដែលមានស្រាប់ ក៏នៅបន្តមានបញ្ហាប្រឈមមួយចំនួន ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងសុខភាពសហគមន៍ក្នុងរយៈពេលយូរអង្វែង។ គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន២ (LASED-II) បានប្រើវិធីសាស្ត្រការពារសុវត្ថិភាពដោយផ្អែកលើផែនទីភូមិសាស្ត្រជាក់លាក់ មិនបានគិតទៅដល់ហានិភ័យដែលមានសក្តានុពល ឬបណ្តាលមកពីកត្តាផ្សេងៗដែលកើតមានឬរាលដាលពីខាងក្រៅតំបន់គោលដៅនោះឡើយ។ បញ្ហាដែលមិនទាន់ត្រូវបានដោះស្រាយគ្រប់ជ្រុងជ្រោយនៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន២ (LASED-II) ប៉ុន្តែសម្រាប់ជំហាន៣ គម្រោងនឹងត្រូវតែដោះស្រាយតាមរយៈការអនុវត្តតាមវិធានការការពារសុវត្ថិភាពយោងតាមបទដ្ឋានបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក រាប់បញ្ចូលទាំងលក្ខខណ្ឌការងារ និងពលកម្មរបស់កម្មករ បញ្ហាសុវត្ថិភាពរួមមាន សុវត្ថិភាពតាមផ្លូវថ្នល់ និងការការពារសិទ្ធិរបស់ជនជាតិដើមភាគតិច។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន៣ នឹងគាំទ្រសកម្មភាពសម្រាប់សម្បទានដីសង្គមកិច្ច (SLC) នៅក្នុងទីតាំង ១៤ កន្លែងដែលមានស្រាប់ និងទីតាំងថ្មីប្រមាណ ១៥ កន្លែងផ្សេងទៀត ។ ដោយឡែកសម្រាប់សហគមន៍ជនជាតិដើមភាគតិច គឺសម្រាប់តែសហគមន៍ចំនួន ៣០ ដែលបានទទួលបណ្ណកម្មសិទ្ធិដីសហគមន៍រួចហើយ និងសហគមន៍ជនជាតិដើមភាគតិច ចំនួន ១៥ ផ្សេងទៀត បានដាក់ពាក្យសុំមកក្រសួងរៀបចំដែនដែនដី នគរូបនីយកម្ម និងសំណង់ ប៉ុន្តែមិនទាន់បានទទួលទទួលបណ្ណ័កម្មសិទ្ធិដីសហគមន៍នៅឡើយ។ LASED-III ជាគម្រោងថ្នាក់មូលដ្ឋាន នឹងជួយគាំទ្រដល់ការអនុវត្តសកម្មភាពនានា នៅក្នុងបណ្តាខេត្តជាច្រើនក្នុងប្រទេសកម្ពុជា ប៉ុន្តែគេរំពឹងថា ខេត្ត

ទាំងឡាយដែលត្រូវផ្តល់សម្បទានដីសង្គមកិច្ចថ្មី (SLC) និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLT) នឹងត្រូវគ្របដណ្តប់នៅក្នុងខេត្តភូមិភាគឦសាន្តចំនួន៦។ តំបន់ទាំងនោះជាខេត្តដែលមានដង់ស៊ីតេប្រជាជនទាប ក្នុងនោះមានជនជាតិដើមភាគតិចប្រហែល ១៤% ប៉ុន្តែ ៦០% នៅក្នុងខេត្តរតនគិរី និង ៤៦% នៅក្នុងខេត្តមណ្ឌលគិរី ដែលជាតំបន់ខ្ពង់រាបភូមិភាគឦសាន្ត។ ចំនួនប្រជាជនមានអាយុមធ្យម ២២ឆ្នាំ និងមានការកើនឡើងលឿនជាងមធ្យមភាគទូទាំងប្រទេស ដោយសារការធ្វើចំណាកស្រុកចូលមកពីបណ្តាខេត្តផ្សេងៗ។ អត្រាភាពក្រីក្រគឺខ្ពស់ជាងមធ្យមភាគថ្នាក់ជាតិ ខណៈការទទួលបានសេវាសាធារណៈនៅមានកម្រិត និងសូចនាករសេដ្ឋកិច្ចសង្គម នៅមានកម្រិតទាបជាងមធ្យមភាគថ្នាក់ជាតិ។ ការងារកសិកម្ម គឺជាសកម្មភាពចម្បងសម្រាប់ទ្រទ្រង់សេដ្ឋកិច្ច និងជីវភាពប្រចាំថ្ងៃ និងមានមនុស្សពេញវ័យត្រឹមតែ ៧% ប៉ុណ្ណោះដែលមានការងារធ្វើផ្លូវការ។ ប្រជាជនចំណាកស្រុកមានប្រហែល ១១% ក្នុងចំណោមមនុស្សពេញវ័យ ប៉ុន្តែមានតិចតួចប៉ុណ្ណោះ សម្រាប់សហគមន៍ជនជាតិដើមភាគតិច។បញ្ហាកុមារកង្វះអាហារូបត្ថម្ភរបស់កុមារ នៅតែជាកង្វល់ចំបងចំពោះសុខភាពកុមារ។ ក្នុងចំណោមជំងឺឆ្លង ក្នុងនោះជំងឺរបេងមាន អត្រាស្លាប់ខ្ពស់បំផុត ប៉ុន្តែអត្រាស្លាប់ដោយសារជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម គឺស្ថិតក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ផងដែរ។ ការស្លាប់ និងរបួសដោយសារសំណល់ជាតិផ្ទុះនៃសង្គ្រាម បានថយចុះយ៉ាងឆាប់រហ័ស ប៉ុន្តែគ្រោះថ្នាក់ចរាចរណ៍កំពុងកើនឡើង ហើយឥឡូវនេះ គឺជាការព្រួយបារម្ភដ៏ធំមួយរបស់ប្រជាពលរដ្ឋ។ អាជ្ញាធរមូលដ្ឋានក៏កំពុងខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយអំពើហិង្សាមកលើស្ត្រីភេទ តែមានកំរិតដោយសារតែសមត្ថភាពនិងទម្លាប់នៅក្នុងសង្គមដែលនៅតែកើតមាន។

សិទ្ធិទទួលបានការកាន់កាប់ដីធ្លី ត្រូវបានកំណត់នៅក្នុងច្បាប់ ប៉ុន្តែការអនុវត្តជាក់ស្តែង ជាញឹកញាប់មិនដូចក្នុងច្បាប់នោះទេ ដោយសារតែកង្វះការវាស់វែងដីជាប្រព័ន្ធ និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ ដីភាគច្រើននៅក្នុងខេត្តគោលដៅមានត្រឹមបង្កាន់ដៃកាន់កាប់ "ប្លង់ទន់" ឬមានការកាន់កាប់ដីធ្លី តាមរយៈការទន្ទ្រានកាន់កាប់ដីរបស់រដ្ឋ រួមទាំងតំបន់អភិរក្ស និងដីសហគមន៍ជនជាតិដើមភាគតិចសម្រាប់ប្រើប្រាស់ជាប្រពៃណីរបស់ពួកគេ (ដែលដីទាំងនេះ សមស្របសម្រាប់ការចុះបញ្ជីកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច)។ បញ្ហាវិវាទដីធ្លី បានក្លាយជារឿងធម្មតាទៅហើយ ដែលក្នុងនោះមានអ្នកពាក់ព័ន្ធជាច្រើនដូចជា សហគមន៍មូលដ្ឋាន និងអ្នកទន្ទ្រានមកពីខាងក្រៅសហគមន៍ និងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចផងដែរ ។ ដីទាំងនេះ ភាគច្រើនត្រូវបានកាន់កាប់ ដោយពុំបានវាស់វែង ឬបានកំណត់ព្រំប្រទល់ច្បាស់លាស់ ឬបានដោះស្រាយចំណោះការតតវ៉ាលើទីតាំងដីត្រួតគ្នានោះទេ។ ការដែលមិនបានកំណត់ព្រំប្រទល់ច្បាស់លាស់ទៅតាមប្រភេទតំបន់នៃដីនៅក្នុងដែនព្រៃការពារក៏ជាការបញ្ហាប្រឈមមួយ ពិសេសនៅតំបន់ដែលនឹងចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ដំណើរការនៃការផ្តល់សម្បទានដីសង្គមកិច្ច និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងគម្រោងនេះ នឹងត្រូវធ្វើឡើង ដោយមានការកំណត់អត្តសញ្ញាណ និងវាយតម្លៃ ទៅលើការទាមទារឬបណ្តឹងតវ៉ាចំពោះដីដែលត្រួតស៊ីគ្នា ដូចជាមាន នៅក្នុងតំបន់ការពារធម្មជាតិ រាប់បញ្ចូលទាំងតំបន់ងាយរងផលប៉ះពាល់ដល់ជីវចម្រុះ ដីសម្បទានសេដ្ឋកិច្ច ព្រមទាំងដីឯកជនដែលមានកម្មសិទ្ធិស្របច្បាប់ដែលត្រូវផាត់ចេញ និងដីឯកជនដែលមិនមានកម្មសិទ្ធិស្របច្បាប់ ក៏នឹងត្រូវផាត់ចេញដែរ។

តំបន់ភូមិភាគឦសាន្ត នៃប្រទេសកម្ពុជា ជាតំបន់ដែលមានព្រៃឈើពោរពេះដោយជីវចំរុះច្រើននៅឡើយ ក្នុងនោះមានប្រហែល ៥០% ដែលជាតំបន់ព្រៃការពារធម្មជាតិ (ព្រៃឈើ និងដែនជម្រកសត្វ។ល។) ជីវចម្រុះនេះស្ថិតនៅក្រោមការគម្រាមកំហែងពីការកាប់បំផ្លាញព្រៃឈើនិងការបំលែងដីសម្រាប់កសិកម្មក៏ដូចជាពីសកម្មភាពខុសច្បាប់ដូចជាការកាប់យកឈើមានតំលៃខ្ពស់ ការបរបាញ់រួមទាំងប្រភេទសត្វដែលជិតផុតពូជ និងការជុតត្បូងជាដើម។ សហគមន៍ក្នុងតំបន់ព្រៃឈើពឹងផ្អែកលើផលិតផលព្រៃឈើសម្រាប់ផ្នែកសំខាន់មួយនៃជីវភាពរស់នៅរបស់ពួកគេ ប៉ុន្តែដោយសារការខ្វះខាត - ពួកគេអាចចូលរួមក្នុងសកម្មភាពខុសច្បាប់និងបំផ្លាញ។ តំបន់សម្រាប់សម្បទានដីសង្គមកិច្ចថ្មី (SLC) និងចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLT) ក៏មានទីតាំងនៅជិតតំបន់ដែលសម្បូរជីវៈចម្រុះផងដែរ។

បំរែបំរួលអាកាសធាតុត្រូវបានគេព្យាករណ៍ថា នឹងបណ្តាលឱ្យមានរដូវប្រាំង និងរាំងស្ងួតកាន់តែយូរហើយរដូវវស្សាក៏មានស្ថានភាពតំហុកខ្លាំង សីតុណ្ហភាពកើនឡើង ព្រមទាំងគ្រោះធម្មជាតិដែលកាន់តែកើតឡើងញឹកញាប់និងធ្ងន់ធ្ងរ។ ធនធានទឹកគឺអាស្រ័យទៅលើទឹកភ្លៀងនិងលំហូរចូលឆ្លងដែននៃទន្លេមេគង្គនិងទន្លេដែលពាក់ព័ន្ធ។ ទាំងនេះស្ថិតនៅក្រោមសម្ពាធពីការប្រែប្រួលអាកាសធាតុ និងពីការសាងសង់ទំនប់វារីអគ្គិសនីដែលចំណុចនេះ ជួនកាល ក៏មានផលប៉ះពាល់អវិជ្ជមានក្នុងតំបន់ទៅលើសហគមន៍ខ្សែទឹកខាងក្រោម ដែលក្នុងនោះក៏អាចមានផលប៉ះពាល់មកលើតំបន់សម្រាប់សម្បទានដីសង្គមកិច្ចថ្មី (SLC) និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLT) ដែរ។ សហគមន៍មូលដ្ឋានពឹងផ្អែកលើទឹកអូរជាច្រើន និងទឹកក្រោមដី តែគេឃើញមានហានិភ័យនៃកម្រិតអាសេនិកដែលអាចបង្កគ្រោះថ្នាក់នៅក្នុងទឹកក្រោមដី នៅក្នុងតំបន់ខ្លះ។ មានហានិភ័យនៃកម្រិតអាសេនិកដែលបង្កគ្រោះថ្នាក់នៅក្នុងទឹកក្រោមដីនៅក្នុងតំបន់ខ្លះ។ ដោយ សារគម្រោងនេះនឹងពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីតាំងសហគមន៍ ទៅកាន់តំបន់សម្រាប់សម្បទានដីសង្គមកិច្ចថ្មី (SLC) ចំណុចប្រឈមមុខសញ្ញាគ្រោះថ្នាក់ទាំងនេះត្រូវតែចាត់ទុកថាជា ហានិភ័យដែលអាចប៉ះពាល់សុខភាពនិងសុវត្ថិភាពសហគមន៍ទាក់ទងនឹងគម្រោងនេះ។

មានហានិភ័យដែលគេបានរកឃើញជាមុនគឺជាតិអាសេនិកនៅក្រោមដី នៅក្នុងតំបន់ខ្លះ ។ ប្រភពនៃការបំពុលបរិស្ថាន (pollution sources) នៅក្នុងខេត្តគោលដៅ រាប់បញ្ចូល ការប្រើប្រាស់សារធាតុគីមីនៅក្នុងកសិដ្ឋានធំៗ និងការបំពុលដោយសារធាតុគីមី ពីសកម្មភាពរុករករ៉ែ ។ល។ ទាំងនេះគឺជាហានិភ័យដែលមានសក្តានុពលប៉ះពាល់ដល់តំបន់សម្បទានដីសង្គមកិច្ច (SLC) និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLT) របស់គម្រោង បើទីតាំងដីឬភូមិស្ថិតនៅខ្សែទឹកខាងក្រោម។ ដោយសារគម្រោងនេះ មានពាក់ព័ន្ធក្នុងការផ្លាស់ទីតាំងសហគមន៍ ដោយអនុញ្ញាតិអោយមកតាំងទីលំនៅតំបន់សម្បទានសង្គមកិច្ច បញ្ហាខាងលើនេះ អាចមានផលប៉ះពាល់មកលើសុខភាព និងសុវត្ថិភាពរបស់សហគមន៍ នៅក្នុងគម្រោង។

ហានិភ័យចំពោះបរិស្ថាន និងសង្គម ត្រូវបានគេរកឃើញ ហើយវិធានការគ្រប់គ្រងហានិភ័យទាំងនោះ ក៏ត្រូវបានកំណត់នៅក្នុងឯកសារគោលស្តីពីក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គម រួមមាន÷ ១) ហានិភ័យប៉ះពាល់ផ្ទាល់

ចំពោះពលករនៅក្នុងគម្រោង សំខាន់ជាងនេះទៀត គឺការធ្វើដំណើរ និងការបំពេញការងារនៅតាមទីតាំងសហគមន៍ដាច់ស្រយាលទាំងនោះ។ ២) លក្ខខ័ណ្ឌ និងសុវត្ថិភាពការងារ របស់កម្មករជាប់កិច្ចសន្យា ជាពិសេសកម្មករសំណង់។ ៣) ការប្រើប្រាស់ប្រភពទឹកដោយគ្មាននិរន្តរភាព ជាពិសេសសម្រាប់ប្រព័ន្ធធារាសាស្ត្រ។ ៤) ការបំពុលបរិស្ថានដែលបង្កឡើងដោយកសិករប្រើប្រាស់សារធាតុគីមីមិនត្រឹមត្រូវ នៅក្នុងការងារកសិកម្ម រួមទាំងកាកសំណល់មុខសញ្ញាគ្រោះថ្នាក់ និងមិនគ្រោះថ្នាក់ ចេញពីការងារសំណង់។ ៥) ហានិភ័យនៃទំនប់ទឹក រួមមាន គម្រោងទំនប់ទឹកនៅតំបន់ខាងលើៗ។ ៦) សំណល់ជាតិផ្ទុះនៃសង្គ្រាម ។ ៧) ជំងឺឆ្លង និងជំងឺឆ្លងតាមទឹក។ ៨) ផលប៉ះពាល់លើសុខភាពដោយសារការផ្គត់ផ្គង់ទឹកមិនស្អាត ឬទឹកមានជាតិពុល។ ៩) គ្រោះថ្នាក់ចរាចរណ៍។ ១០) ផលប៉ះពាល់អវិជ្ជមានដែលបណ្តាលឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភកុមារ ការកាត់បន្ថយលទ្ធភាពទទួលបានសេវាសុខភាព ការគាំទ្រដល់ជនរងគ្រោះដោយសារអំពើហិងលើស្ត្រី (បញ្ហាយេនឌ័រ)។ ១១) មុខសញ្ញាគ្រោះថ្នាក់នៅទីសាធារណៈ ដោយសារការងារសំណង់។ ១២) ផលប៉ះពាល់អវិជ្ជមានដលអ្នកប្រើប្រាស់ដីធ្លី រួមទាំងម្ចាស់ដីស្របច្បាប់ និងមិនស្របដែលមិនអាចការពារបានដោយច្បាប់កម្ពុជា និងអ្នកប្រើប្រាស់ដីនៅក្នុងតំបន់ដីធ្លីនិងធនធានជាតិដែលប្រើប្រាស់រួមគ្នា។ ល។ ១៣) ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានលើតំបន់ពិសេសជីវចម្រុះក្នុងតំបន់ក្បែរៗទីតាំងគម្រោង ជាពិសេស ការផ្តល់ដីសម្បទានសង្គមកិច្ច។ ១៤) ផលប៉ះពាល់អវិជ្ជមានលើសិទ្ធិកាន់កាប់ដីធ្លី ការប្រកបរបរចិញ្ចឹមជីវិត ឬបេតិកភ័ណ្ឌវប្បធម៌របស់ជនជាតិដើមភាគតិច។ ១៥) សក្តានុពលនៃការខូចខាតដល់បេតិកភណ្ឌវប្បធម៌រូបី ឬអរូបី។

ការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាន និងសង្គម នៅក្នុងគម្រោងបែងចែកដីដើម្បីសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហាន៣ នឹងបែងចែកជា ៣ កម្រិត រួមមាន÷ កម្រិតគម្រោង, កម្រិតទីតាំង (គម្រោង SLC និង ICLT) និងកម្រិតអនុគម្រោង តែមានការផ្តោតជាពិសេសទៅលើកំរិតពីរចុងក្រោយ ដោយសារមានការអនុវត្តសកម្មភាពច្រើនជាងគេបំផុត។ ក្នុងករណីខ្លះ (ឧទាហរណ៍ តំបន់សម្បទាដីសង្គកិច្ច (SLC) មួយចំនួននៅជាប់គ្នា) គេទាមទារអោយមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមជារួមតែម្តង។ ឧបករណ៍គ្រប់គ្រងហានិភ័យនៅកម្រិតគម្រោង រួមមាន÷ ១) ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) និងផែនការប្តេជ្ញាចិត្តផ្នែកបរិស្ថាននិងសង្គម (ESCP); នីតិវិធីគ្រប់គ្រងលក្ខខ័ណ្ឌការងារនិងពលកម្ម (LMP); ក្របខ័ណ្ឌគោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (RPF); ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (IPPF); ក្របខ័ណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF) និងផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ដោយមានរួមបញ្ចូលយន្តការដោះស្រាយទំនាស់ (GRM) ផងដែរ។ គម្រោងនេះក៏នឹងមានរៀបចំ ផែនការប្រតិបត្តិសុខភាពនិងសុវត្ថិភាព សម្រាប់កម្មករបម្រើការនៅក្នុងគម្រោងដោយផ្ទាល់ និងបទដ្ឋានបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព ក៏ត្រូវដាក់បញ្ចូលទៅក្នុងឯកសារកិច្ចសន្យារបស់ពលករ ព្រមទាំងវិធានការណ៍បរិស្ថាននិងសង្គមផ្សេងៗទៀតដែរ ។

ការវាយតម្លៃហានិភ័យបរិស្ថាននិងសង្គមជំហានដំបូង នឹងត្រូវបានអនុវត្តនៅពេលចាប់ផ្តើមសកម្មភាពនៅតាមទីតាំងនីមួយៗ និងត្រូវកំណត់លក្ខខ័ណ្ឌជាក់លាក់ នៅក្នុងឬនៅជិតទីតាំងគម្រោង ដោយកំណត់ហានិភ័យទាំងឡាយណា

ដែលពាក់ព័ន្ធ នៅក្នុង ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) (ក៏ដូចជា កត្តាហានិភ័យជាក់លាក់ដទៃទៀត ដែលអាចកើតមាននៅក្នុងទីតាំងទាំងនោះ)។ ផ្អែកលើការវាយតម្លៃជំហានដំបូង ផែនការគ្រប់គ្រងបរិស្ថាននិងសង្គមដែលពាក់ព័ន្ធនឹងរៀបចំឡើង រួមជាមួយនឹងផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) (នៅតាមទីតាំងទាំងអស់); ផែនការដោះស្រាយផលប៉ះពាល់លើការផ្លាស់ទីលំនៅដោយសារគម្រោង (RP); ផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច (IPP) និងផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ (CHMP) ។ គោលការណ៍នៃការសម្រេចចិត្តដោយសេរី បានដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (FPIC) នឹងត្រូវយកមកអនុវត្ត នៅតាមទីតាំងទាំងឡាយណា ដែលមានសក្តានុពលប៉ះពាល់ជាអវិជ្ជមាន ដល់ជនជាតិដើមភាគតិច។

រាល់អនុគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងការប្រកបរបរចិញ្ចឹមជីវិត នឹងត្រូវឆ្លងកាត់ការវាយតម្លៃជំហានដំបូងសម្រាប់ការកំណត់ហានិភ័យចំពោះបរិស្ថាននិងសង្គម ដោយប្រើប្រាស់ទម្រង់សាមញ្ញនៃផែនការសម្រាប់គ្រប់គ្រងបរិស្ថាននិងសង្គម (ESMP)។ ផែនការសាមញ្ញ នឹងដាក់បញ្ចូលនូវខ្លឹមសារតាមប្រភេទអនុគម្រោង និងខ្លឹមសារជាក់លាក់ដែលបានរកឃើញនៅក្នុងការវាយតម្លៃជំហានដំបូង។ ទម្រង់សាមញ្ញសម្រាប់អនុគម្រោង ក៏មានដាក់បញ្ចូលលក្ខខ័ណ្ឌលម្អិតនៅក្នុងឯកសារគោលស្តីពី បរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព ESHS (រាប់ទាំងការរៀបចំកិច្ចសន្យាជាមួយកម្មករ, សុវត្ថិភាព និងសុខភាពនៅតាមទីតាំង ការត្រួតពិនិត្យការបំពុលបរិស្ថាន, សុវត្ថិភាពសហគមន៍ក្នុងកំឡុងពេលសាងសង់ ព្រមទាំងគិតគូរអំពី ឧប្បត្តិហេតុនៃសំណល់ជាតិផ្ទុះនៃសង្គ្រាម)។ ការស្ថាបនាទំនប់ទាំងអស់ នឹងត្រូវត្រួតពិនិត្យសុវត្ថិភាពជាចម្បង។ ការស្ថាបនាផ្លូវក៏ត្រូវ ត្រួតពិនិត្យមើលការរចនាប្លង់ទាំងអស់ ដើម្បីធានាសុវត្ថិភាពចរាចរណ៍) នឹងត្រូវដាក់បញ្ចូលនៅក្នុងការរៀបចំកិច្ចសន្យា។ ការសាងទំនប់ទឹកទាំងអស់ នឹងត្រូវឆ្លងកាត់ការពិនិត្យទៅលើសុវត្ថិភាព។ ការកសាងផ្លូវថ្នល់នៅតាមទីតាំង ក៏នឹងមាននឹងផែនការនិងការត្រួតពិនិត្យលើសុវត្ថិភាពដែរ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហាន៣ នឹងបង្ហាញព័ត៌មានសំខាន់ៗ ឲ្យបានទាន់ពេលវេលាដល់ភាគីពាក់ព័ន្ធ និងភាគីដែលរងផលប៉ះពាល់ សម្រាប់គម្រោងទាំងមូល ស្របតាមផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ(SEP) ក្នុងកំរិតគម្រោង ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ(SEP)នៅក្នុងកំរិតទីតាំងនីមួយៗ និងតម្រូវការស្តង់ដារដែលបានតាក់តែងឡើងសម្រាប់ដំណើរការផ្តល់សម្បទាដីសង្គមកិច្ច (SLC) និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLT)។ ការជំរុញឲ្យមានការចូលរួមរបស់ជនជាតិដើមភាគតិច សមស្របតាមវប្បធម៌របស់គេ ដោយប្រើប្រាស់ភាសាមូលដ្ឋានរបស់ជនជាតិដើមភាគតិច ទៅតាមលទ្ធភាពដែលអាចធ្វើបាន។ គម្រោងនឹងជ្រើសរើសអ្នកសម្របសម្រួលសហគមន៍ ចេញពីសហគមន៍ជនជាតិដើមភាគតិច ដើម្បីជួយសម្របសម្រួលក្នុងដំណើរការពិគ្រោះយោបល់នេះ។ គម្រោងនេះនឹងបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា ដូចមានរៀបរាប់នៅក្នុងឯកសារផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP)។ បណ្តឹងតវ៉ាទាំងឡាយណា ដែលអាចកើតឡើងក្នុងអំឡុងពេលអនុវត្តសកម្មភាពគម្រោង នឹងត្រូវដោះស្រាយជាដំបូង តាមរយៈដំណើរការដំណោះស្រាយបណ្តឹងតវ៉ា តាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច (IP) ហើយនិង គម្រោងនឹងជួយគាំទ្រក្នុងដំណើរការដោះស្រាយបណ្តឹងតវ៉ា (GRM) ជាបន្តបន្ទាប់មកទៀត ដោយចេញ

សោហ៊ុយចំណាយផងដែរ សម្រាប់សមាជិកសហគមន៍ណាម្នាក់ដែលឈរជាតំណាងក្នុងដំណើរការបណ្តឹងតវ៉ា។ ការជំរុញឲ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធ ក្នុងអំឡុងពេលរៀបចំគម្រោង ត្រូវបានពិពណ៌នាលំអិត នៅក្នុងផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP)។

ការអនុវត្តសកម្មភាពគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គម គឺជាការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តគម្រោង និងដៃគូ ទាំងអស់ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយត្រូវជ្រើសរើសអ្នកឯកទេសផ្នែកបរិស្ថាន ១នាក់, អ្នកឯកទេសផ្នែកសង្គម ១នាក់, ទីប្រឹក្សាផ្នែកជនជាតិដើមភាគតិច ១នាក់ និងទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គមមួយចំនួនទៀត នៅថ្នាក់ខេត្ត។ ស្ថាប័នអនុវត្តទាំងអស់ នឹងតែងតាំងមន្ត្រីជនបង្គោលផ្នែកបរិស្ថាន ១នាក់ និងសង្គម ១នាក់។ ក្នុងករណីគម្រោងត្រូវការដីសម្រាប់គម្រោង ដែលតម្រូវអោយអ្នកកាន់កាប់ដីផ្លាស់ទីតាំងដោយមិនមានការស្ម័គ្រចិត្ត, ផែនការដោះស្រាយសំណងលើការផ្លាស់ទីតាំងថ្មីដោយសារគម្រោង (RP) នឹងត្រូវបានរៀបចំឡើងនិងអនុវត្តដោយ អគ្គនាយកដ្ឋាននៃការតាំងទីលំនៅថ្មី នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គម្រោងនេះនឹងត្រួតពិនិត្យតាមដាន និងរាយការណ៍អំពីការអនុវត្តការគ្រប់គ្រង រួមបញ្ចូលទាំងការគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គម ព្រមទាំងព្រឹត្តិការណ៍ប្រែប្រួលនានា ដែលទាក់ទងជាមួយបរិស្ថាន និងសង្គម។ ការត្រួតពិនិត្យការអនុវត្តន៍តាមបទដ្ឋានបរិស្ថាននិងសង្គម នឹងត្រូវចាប់ផ្តើមអនុវត្តនៅមុនពេលវាយតម្លៃគម្រោងនៅពាក់កណ្តាលអាណត្តិ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងសេដ្ឋកិច្ចដំហាន៣ នឹងអនុវត្តផែនការកសាងសមត្ថភាពគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម ដែលបង្ហាញនៅក្នុងឯកសារស្តីពីក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF)។ អ្នកដែលត្រូវចូលរៀនវគ្គបណ្តុះបណ្តាល រួមមាន÷ ១) មន្ត្រីគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គម។ ២) កម្មករធ្វើការផ្ទាល់ជាមួយគម្រោង ដោយបណ្តុះបណ្តាលពួកគេនូវចំណេះដឹងមូលដ្ឋានទាក់ទងនឹងទំនួលខុសត្រូវរបស់ពួកគេ ក្នុងពេលបំពេញការងារ។ ៣) បុគ្គលិកនៃអង្គការដៃគូដទៃទៀត។ និង ៤) បុគ្គលិកត្រួតពិនិត្យរបស់ក្រុមហ៊ុនម៉ៅការគម្រោង។

ការចំណាយលើការអនុវត្តវិធានគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម (ESMF) មានរួមបញ្ចូលការចំណាយជាក់លាក់ និងចំណាយថវិកាគម្រោងទូទៅ។ តម្រូវការថវិកា សម្រាប់ការអនុវត្តសកម្មភាព (ESMF) មួយនេះ មានប្រមាណ ១,០៧៨,០០០ ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះថវិកាប្រមាណ ៥០០,០០០ ដុល្លារសហរដ្ឋអាមេរិក គឺជាប្រាក់ខែសម្រាប់ទី-ប្រឹក្សាគម្រោង។

ឯកសារក្របខ័ណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម (ESMF) រាប់បញ្ចូលទាំងឯកសារដូចជាផែនការគ្រប់គ្រងបរិស្ថាននិងសង្គម (ESP); ផែនការគ្រប់គ្រងលក្ខខ័ណ្ឌការងារនិងពលកម្ម (LWCP) ក្របខណ្ឌ័គោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង (RPF); ក្របខណ្ឌ័ផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច (IPPF) និងក្របខណ្ឌ័ការពារបេតិកភណ្ឌវប្បធម៌ (CHPF) ត្រូវយកទៅផ្សព្វផ្សាយឬពិគ្រោះយោបល់ជាមួយឯកសារស្តីពី ផែនការប្តេជ្ញាចិត្តសម្រាប់គ្រប់គ្រងបរិស្ថាន និងសង្គម (ESCP) និង ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ(SEP)។

ដោយមើលឃើញពីវិធានការណ៍របស់រដ្ឋាភិបាលដើម្បីចៀសវាងការរីករាលដាលនៃ COVID-19 ការពិគ្រោះយោបល់ដោយផ្ទាល់ តាមរយៈការរៀបចំសិក្ខាសាលាមិនអាចធ្វើទៅបានទេ ដូច្នេះការពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញ នឹងត្រូវបានប្រើប្រាស់ តាមកាលៈទេសៈសមស្រប។ ដូចដែលបានព្រមព្រៀងជាមួយធនាគារពិភពលោករួចហើយ ដំណើរការពិគ្រោះយោបល់នឹងអនុវត្តតាមវិធីសាស្ត្រ ៣ យ៉ាងរួមមាន អ៊ិនធឺរណែត ការហៅទូរស័ព្ទ / អ៊ីមែល។ល។ អ្នកពាក់ព័ន្ធដែលត្រូវពិគ្រោះយោបល់តាមរយៈដំណើរការនេះ រួមមានអ្នកពាក់ព័ន្ធនៅខេត្តក្រចេះ មណ្ឌលគិរី និងរតនគិរី នៅថ្នាក់ឃុំ និងថ្នាក់សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជា ភាគីពាក់ព័ន្ធនៅថ្នាក់ជាតិផងដែរ។

មតិយោបល់របស់អ្នកពាក់ព័ន្ធ ត្រូវយកមកកែលំអរបញ្ចប់ឯកសារក្របខ័ណ្ឌស្តីពីគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម និងឧបករណ៍ពាក់ព័ន្ធការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គមផ្សេងៗទៀត។